# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខៈ ០៥០៩/១៩ ក.អ.ជ

ថ្ងៃពុធ ៦ កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៩

# របាយការណ៍
## វឌ្ឍនភាពការងារប្រចាំត្រីមាសទី ១ ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

### I. សេចក្តីផ្តើម

ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ នេះ ព្រះរាជាណាចក្រកម្ពុជាបានទទួលអាកាសធាតុក្តៅខ្លាំងជាងសព្វមួយដងគ្របដណ្តប់នៅទូទាំងប្រទេស ។ ទឹកបឹង ស្រះ ត្រពាំង អណ្តូង អាងដំកល់ទឹក ព្រែក ស្ទឹង មួយចំនួន រីង គោក បង្កការខ្វះខាតទឹកសម្រាប់ប្រើប្រាស់ បរិភោគ និងដាំដំណាំដល់ប្រជាពលរដ្ឋក្នុងសហគមន៍ជនបទ។ ប្រឈមនឹងបញ្ហានេះក្រសួងបានចេញសេចក្តីណែនាំដល់មន្រ្តីជំនាញគ្រប់លំដាប់ថ្នាក់ចុះពិនិត្យ និងជួយដោះស្រាយបញ្ហាកង្វះទឹកជូនប្រជាពលរដ្ឋតាមរយៈស្តារស្រះ ជួសជុលអណ្តូងស្នប់ និងណែនាំប្រជាពលរដ្ឋឲ្យចេះរក្សាទឹកទុកប្រើប្រាស់ក្នុង រដូវប្រាំងនេះ ឲ្យបានល្អ ដើម្បីបន្តប្រើប្រាស់រហូតដល់មានភ្លៀងធ្លាក់ ។

ការផ្តល់សេវាជូនប្រជាពលរដ្ឋលើការងារស្ថាបនា ជួសជុលលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្តគមនាគមន៍ជនបទរួមមាន សាងសង់ ជួសជុល ថែទាំផ្លូវ ស្ពាន ប្រឡាយទឹក អណ្តូងទឹក ស្រះទឹក បង្គន់អនាម័យ អប់រំ ផ្សព្វផ្សាយសេវាទឹកស្អាត អនាម័យ ការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (ODF) រៀបចំទិវាលាងសម្អាតដៃ ការងារបរិស្ថានតាមភូមិ ដើម្បីធានាលើកកម្ពស់លក្ខខណ្ឌរស់នៅឲ្យបានល្អប្រសើរ កំពុងដំណើរការតាមផែនការដែលបានគ្រោងទុក ។ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានបង្កើតការងារ មុខរបរ សម្រាប់អាជីវកម្មខ្នាតតូច តាមសហគមន៍ជនបទព្រមទាំងផ្តល់សេវាឥណទានខ្នាតតូចដើម្បីបង្កើតមុខរបរសមស្របក្នុងសហគមន៍មូលដ្ឋាន ។ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងអង្គការមិនមែនរដ្ឋាភិបាលផងកំពុងបន្តសកម្មភាពដោយរលូន។ សមិទ្ធផលសម្រេចបានក្នុងត្រីមាសទី១ ឆ្នាំ ២០១៩ មានដូចខាងក្រោមៈ

### II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

#### ១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ត្រីមាសទី ១ ឆ្នាំ ២០១៩ មន្រ្តីរាជការក្របខណ្ឌសរុបមានចំនួន ១ ៨០៨ នាក់ ។ ក្រសួងបានទទួលលិខិតចូលចំនួន ៤៥៨ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ៣៦១ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានា ចំនួន ៩៨ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២ ៦៤៤ ច្បាប់ ។

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

ក្នុងត្រីមាសទី ១ ឆ្នាំ ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិសរុប ចំនួន ៤៥ ករណី ដែលក្នុងនោះបានដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ០៥ ករណី ។

៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងត្រីមាសទី ១ ឆ្នាំ ២០១៩ ក្រសួងបានអនុវត្តចំណាយ ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩ សម្រេចៈ

- ចំណាយចរន្តអនុវត្តបានចំនួន ៤ ១៣៨ ៧៩០ ២៩៥ រៀល ស្មើនឹង ៣,១៦% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ៤ ៣៨៩ ៦០៤ ០០០ រៀល ស្មើនឹង ២,៣១% នៃច្បាប់ថវិកា ។

៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមប្រជុំរៀបចំសិន្និបាតក្រសួងដឹកនាំដោយ ឯកឧត្តម សួស គង់ រដ្ឋលេខាធិការប្រចាំការ នៅទីស្តីការក្រសួង
- ចូលរួមប្រជុំស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ លើការងារផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ និងគម្រោងបញ្ចូលការងារនេះក្នុងថវិកាកម្មវិធីឆ្នាំ២០២០ ខាងមុខនេះ
- ចូលរួមកិច្ចប្រជុំគណៈកម្មការពិគ្រោះយោបល់ ស្តីពីផលប៉ះពាល់នៃកម្មវិធីប្រែប្រួលអាកាសធាតុនៅកម្ពុជា ទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ និងយេនឌ័រ ចំនួន ២ លើក
- ចូលរួមកិច្ចប្រជុំពិភាក្សាលើការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ ឆ្នាំ ២០១៩ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុចំនួន ២ លើក
- ចូលរួមប្រជុំពិគ្រោះយោបល់ស្តីពី ការងារអង្គការមិនមែនរដ្ឋាភិបាលបរទេស FNGOs នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចូលរួមកិច្ចប្រជុំក្រុមសម្របសម្រួល អេឡិចត្រូនិច និងការគ្រប់គ្រង វេបសាយក្រសួង ដឹកនាំដោយឯកឧត្តមបណ្ឌិត ចាន់ ដារ៉ុង រដ្ឋលេខាធិការ នៅទីស្តីការក្រសួង
- ចូលរួមប្រជុំពិភាក្សាលទ្ធផលនៃការរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ (MAP3) ឆ្នាំ២០១៩ របស់ក្រុមកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំកិច្ចប្រជុំប្រចាំខែមករា ឆ្នាំ២០១៩ របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ដឹកនាំដោយ ឯកឧត្តម សៅ ជីវ័ន្ត រដ្ឋលេខាធិការ
- ចូលរួមពិធីប្រកាសដាក់ឲ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ FMIS ក្រោមអធិបតីភាព ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ជួបពិភាក្សាជាមួយអង្គការ Engineering without borders ស្តីពីការរៀបចំលិខិតគាំទ្រសុំចុះកិច្ចព្រមព្រៀងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- ជួបពិភាក្សាជាមួយអង្គការ World Vision លើការងារសហការជាមួយក្រសួង និងរបាយការណ៍ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បញ្ចប់ការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទ ២០១៩-២០២៣
- ប្រមូលធាតុចូលស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២០-២០២២
- ចូលរួមសម្ភាសន៍ការងារបណ្តុះបណ្តាលធនធានមនុស្សរបស់វិទ្យាស្ថាន EFI មកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រជុំពិភាក្សាជាមួយអង្គការ សមាគមសម្របសម្រួល និងអភិវឌ្ឍន៍សង្គម នៅទីស្តីការក្រសួង ដឹកនាំដោយ ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្រ្តីក្រសួងអភិវឌ្ឍន៍ជនបទ
- ជួបពិភាក្សាជាមួយអង្គការក្រៅរដ្ឋាភិបាល នៅទីស្តីការក្រសួងបានចំនួន០២ លើក
- ចុះបំពេញបេសកកម្មផ្សព្វផ្សាយណែនាំការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២០-២០២២ និងពិនិត្យមើលការអនុវត្តផែនការឆ្នាំ២០១៨ និងផែនការថវិកាឆ្នាំ២០១៩ នៅខេត្តក្រចេះ ស្ទឹងត្រែង និងរតនគីរី
- ចូលរួមកិច្ចប្រជុំអនុគណៈកម្មាធិការចម្រុះសេដ្ឋកិច្ចលើកទី១១ និងអនុគណៈកម្មាធិការចម្រុះ វប្បធម៌ និងបរិស្ថានលើកទី១២ សម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងកិច្ចប្រជុំពាក់ព័ន្ធក្រោមអធិបតីភាព ឯកឧត្តម ប៉ាន់ សូរសក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៅទីរួមខេត្តក្រចេះ
- ចូលរួមសិក្ខាសាលាស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងយេនឌ័រ ដែលរៀបចំឡើងដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា (CDRI) នៅសណ្ឋាគារភ្នំពេញ
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសទឹកស្អាត និងអនាម័យលើកទី៣០ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួង
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០២០-២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម សួស គង់ រដ្ឋលេខា ធិការប្រចាំការ នៅសណ្ឋាគារអង្គរខេមរា ខេត្តសៀមរាប
- ចូលរួមពិភាក្សាការរៀបចំសិក្ខាសាលាកម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០២០-២០២២ ដឹកនាំដោយ ឯកឧត្តមបណ្ឌិត សៅ ជីវន្តុ រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួង
- ចុះណែនាំពីការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តរតនគិរី
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីនៅខេត្តចំនួន ០៦ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម កែប កំពត កំពង់ធំ និងខេត្តសៀមរាប
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាល បានចំនួន ០៩ អង្គការ

- បានផ្តល់លិខិតអន្តរាគមន៍ដើម្បីនាំចូលរថយន្ត ជូនអង្គការចំនួន ០២ ច្បាប់
- បានផ្តល់លិខិតអន្តរាគមន៍ដើម្បីសុំចុះបញ្ជីស្លាកលេខ ONG សម្រាប់ទោចក្រយានយន្ត និងរថយន្ត ជូនអង្គការចំនួន ០២ ច្បាប់
- បានផ្តល់លិខិតអន្តរាគមន៍ដើម្បីនាំចូលកង់ចំនួន ១៩៤ គ្រឿង ទំងន់ ៨ ៣៤១,២៥ គីឡូក្រាម ជូនអង្គការទស្សនៈពិភពលោក( World Vision )
- បានចុះពិនិត្យការងារជាក់ស្តែងរបស់អង្គការមិនមែនរដ្ឋាភិបាលនៅខេត្តមណ្ឌលគិរី ក្រចេះ ព្រះវិហារ ស្ទឹងត្រែង សៀមរាប និងខេត្តបាត់ដំបង ។

**៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ចូលរួមកិច្ចប្រជុំប្រកាសស្តីពីការដាក់ឲ្យដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាហិរញ្ញវត្ថុ (FMIS) សាកល្បងសម្រាប់១០ ក្រសួង និងមន្ទីរហិរញ្ញវត្ថុទាំង ២៥ រាជធានីខេត្ត
- បញ្ចប់ការកែសម្រួលផែនការសកម្មភាពដំណាក់កាលទី៣ ( MAP3 ) ឆ្នាំ ២០១៩
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២០-២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម សួស គង់ រដ្ឋលេខាធិការ ប្រចាំការ នៅសណ្ឋាគារអង្គខេមរ ខេត្តសៀមរាប
- កែសម្រួលសមាសភាពក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ប្រជុំរៀបចំផែនការលទ្ធកម្មក្រសួង
- ចុះតាមដានការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៩ នៅតាមមន្ទីរខេត្តចំនួន២គឺ ខេត្តកំពង់ធំ និងខេត្តសៀមរាប
- រៀបចំដាក់ឲ្យដំណើរការប្រព័ន្ធ FMIS របស់ក្រសួង
- រៀបចំរបាយការណ៍ចំណូល ចំណាយ និងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត MAP3 ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កែលម្អការរៀបចំកម្មវិធីចំណាយប្រចាំត្រីមាសឱ្យកាន់ តែមានសុក្រឹត្យភាព
- ពង្រឹងការរៀបចំកិច្ចប្រតិបត្តិការ គណនេយ្យ និងធ្វើការផ្ទៀងផ្ទាត់ជាមួយគណនី
- ត្រួតពិនិត្យ រៀបចំប្រព័ន្ធ និងយន្តការនៃការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងថ្នាក់កណ្តាល និងអង្គភាពថ្នាក់ក្រោមជាតិ
- តាមដានវឌ្ឍនភាពនៃការអនុវត្តការធ្វើរបាយការណ៍តាមទម្រង់របាយការណ៍ថ្មី
- ផ្សព្វផ្សាយផែនការលទ្ធកម្ម ប្រចាំឆ្នាំ និងការប្រគល់កិច្ចសន្យា
- ផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ លើគេហទំព័រ
- ធ្វើបច្ចុប្បន្នភាពឈ្មោះកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ទាំង២៥
- តាមដានការអនុវត្តអនុសាសន៍របស់សវនករដែលបានលើកឡើង

៦. ការងារអធិការកិច្ច និងសវនកម្ម

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការឆ្នាំ២០១៨
- ចូលរួមកិច្ចប្រជុំក្រុមជនបង្គោលប្រឆាំងអំពើពុករលួយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីមូលដ្ឋានគ្រឹះគណនេយ្យ និងការចុះបញ្ជី សម្រាប់ការអនុវត្តគម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៨-២០១៩ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០៤ រួមមាន ខេត្តព្រៃវែង ស្វាយរៀង ប៉ៃលិន និងខេត្តបាត់ដំបង ។

## III. សកម្មភាពការងារជំនាញ

១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ

- គម្រោងសាងសង់ ជួសជុលផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៨ ជំពូក២១ មាន១០៥ គម្រោងកំពុងបន្តដំណើរការការដ្ឋានបានចំនួន ១០៣គម្រោង លទ្ធផលគិតជាមធ្យមស្មើនឹង ៨៤ % ក្នុងនោះមាន ៖
    - ផ្លូវកៅស៊ូប្រវែង ៨២,៣៥ គ.ម
    - ផ្លូវបេតុងប្រវែង ៦,៧៤៤ គ.ម
    - ផ្លូវក្រាលក្រួសក្រហមប្រវែង ៣៨៧,៨៦ គ.ម
    - សំណង់លូមូល លូជ្រុង ៥៦៤ កន្លែង
    - ស្ពានបេតុងចំនួន ២៦ កន្លែង ប្រវែង ១៣១១ម
- ការងារថែទាំខួប ប្រចាំ និងជួសជុលបន្ទាន់ឆ្នាំ ២០១៩ កំពុងដំណើរការនីតិវិធី ។

២. ការងារផ្គត់ផ្គង់ទឹកជនបទ

- ជួសជុលអណ្តូងស្នប់ ចំនួន ០១ នៅខេត្តព្រះវិហារ
- បានចូលរួមសិក្ខាសាលា ស្តីពីការផ្លាស់បទពិសោធន៍លើការងារប្រែប្រួលអាកាសធាតុនៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ
- បានជួបពិភាក្សាការងារអំពីការសិក្សាគម្រោងប្លង់ប្រព័ន្ធចែកចាយទឹកស្អាតខ្នាតតូចសហគមន៍ នៅឃុំចន្ទ្រា ស្រុកចន្ទ្រា ខេត្តស្វាយរៀង
- បានខួងអណ្តូងជូនកងពលតូចទ័ពធ័ត្រយោង និងគ្រួសារទ័ពចំនួន ០២ អណ្តូង នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយគម្រោងឧបត្ថម្ភធនដល់គ្រួសារក្រីក្រ គ្មានលទ្ធភាពតបណ្តាញទឹកស្អាត នៅស្រុកពោធិ៍រៀង ខេត្តព្រៃវែង និងស្រុកល្វាឯម ខេត្តកណ្តាល ។

៣. ការងារថែទាំសុខភាព និងអនាម័យជនបទ



ផ

- បានសាងសង់បង្គន់អនាម័យចាក់ទឹកតាមផ្ទះឯកជន ចំនួន ៥៥៦ ខ្នងផ្ទះ នៅខេត្តរតនគិរី ខេត្តពោធិ៍សាត់ និងខេត្តកំពង់ចាម
- បានចុះត្រួតពិនិត្យតាមដាន និងបំផុសការលើកកម្ពស់អនាម័យ នៅសង្កាត់ទួលសង្កែI សង្កាត់ទួលសង្កែII និងសង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ចំនួន ០៦ លើក
- បានចុះធ្វើការវាយតម្លៃ និងផ្សព្វផ្សាយគោលការណ៍ណែនាំសហគមន៍ដឹកនាំអនុវត្តអនាម័យ នៅខេត្ត ចំនួន ១០ រួមមានខេត្តកោះកុង ក្រចេះ កំពង់ចាម ព្រះសីហនុ សៀមរាប ឧត្តរមានជ័យ កំពង់ឆ្នាំង កំពង់ស្ពឺ ត្បូងឃ្មុំ និងខេត្តស្វាយរៀង ដែលមានអ្នកចូលរួមសរុប ចំនួន ៥២៦ នាក់ ស្រី ១៨៩ នាក់
- បានចុះជ្រើសរើសទីតាំងដាក់បង្គន់សហគមន៍នៅតាមភូមិគោលដៅ នៅខេត្តកំពង់ចាម ត្បូងឃ្មុំ សៀមរាប កំពង់ឆ្នាំង ប៉ៃលិន កែប កំពង់ស្ពឺ ឧត្តរមានជ័យ កោះកុង ស្វាយរៀង ក្រចេះ និងខេត្តព្រះសីហនុ
- បានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសអំពីការពិនិត្យផ្ទៀងផ្ទាត់ផ្ទៃក្នុង ភូមិ ODF ទៅដល់មន្ត្រីអង្គការ iDE
- បានចូលរួមពិនិត្យផ្ទៀងផ្ទាត់ភូមិ ODF នៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ចំនួន ១៧ ភូមិ ក្នុងឃុំ ជាលទ្ធផលភូមិចំនួន ១៦ជាប់ជាភូមិ ODF ។

៤. ការងារអភិវឌ្ឍន៍សហគមន៍

- ចុះពិនិត្យវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តកំពង់ស្ពឺ ត្បូងឃ្មុំ កំពត កំពង់ចាម តាកែវ ព្រះវិហារ កំពង់ឆ្នាំង ឧត្តរមានជ័យ បន្ទាយមានជ័យ ព្រៃវែង និងខេត្តបាត់ដំបង
- ចុះពិនិត្យវគ្គបណ្តុះបណ្តាល ស្តីពីសួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស្តដល់គ្រួសារសហគមន៍ នៅខេត្តកែប និងខេត្តសៀមរាប
- ចុះពិនិត្យវគ្គបណ្តុះបណ្តាលស្តីពី ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ នៅខេត្តកំពង់ធំ និងខេត្តមណ្ឌលគិរី
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្នុងវគ្គទី ១ ឆមាសទី១ ឆ្នាំ ២០១៩ ចំនួន ០៤ មុខជំនាញ មានសិក្ខាកាមសរុបចំនួន ១១៦ នាក់ ស្រី ៥៤ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានចុះផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀន និងបានបើកវគ្គបណ្តុះបណ្តាលកសិកម្ម ចំនួន ០៦ វគ្គ មានសិក្ខាកាមចូលរួមចំនួន ១២០ នាក់ ស្រី ៤៨ នាក់ ។

៥. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ២៧០ នាក់ ក្នុងនោះស្រីចំនួន ៣៥ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ១៨៣ នាក់ ក្នុងនោះស្រីចំនួន ២៧ នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ចំនួន ០២ នាក់ ក្នុងនោះស្រីចំនួន ០២ នាក់



ក.

- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងដល់មន្ត្រីរាជការទាំងពីរភេទរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ទាក់ទងនឹងអាហារូបករណ៍បានចំនួន ០៥ លើក
- បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី "សហគ្រិនភាព និងការគ្រប់គ្រងសហគ្រាស" មានសិក្ខាកាមចូលរួមចំនួនសរុប ៥៥ នាក់ ស្ត្រី ០៩ នាក់
- បានរៀបចំឯកសារចាត់បញ្ជូនមន្ត្រីដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាល ចំនួន ១១ លើក
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនចំនួន ០៤ មុខជំនាញ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៤ នាក់ ស្រី ៤៨ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមឲ្យចូលរៀនសរុបចំនួន ១៥០ នាក់ ស្រី ៦៥ នាក់ លើមុខជំនាញចំនួន ០៧
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនវគ្គទី ១ ឆមាសទី ១ ឆ្នាំ ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀន ចំនួន ០៤ មុខជំនាញ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៦៣ នាក់ ស្រី ២៨ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនវគ្គថ្មី សម្រាប់ឆមាសទី១ ឆ្នាំ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបើកវគ្គបណ្តុះបណ្តាលសម្រាប់វគ្គទី ១ ឆ្នាំ ២០១៩ មាន ០៣ មុខវិជ្ជា ដែលមានសិក្ខាកាមចូលរៀនចំនួន ៧៧ នាក់ ស្រី ៣៨ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមចូលរៀនតាមវគ្គនីមួយៗ និងបានប្រារព្ធពិធីបើកវគ្គជួសជុល និងថែទាំអណ្តូងស្នប់ចំនួន ០១ វគ្គ មានសិក្ខាកាមសរុបចំនួន ៣០ នាក់ ស្រី ១៩ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ បានផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមឲ្យចូលរៀនតាមវគ្គនីមួយៗ និងបានបើកវគ្គភាសាអង់គ្លេស ចំនួន ០២ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៤១ នាក់ ស្រី ២៦ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បន្តរៀបចំឯកសារមួយចំនួនបន្ថែម និងបានផ្សព្វផ្សាយពីគម្រោងវគ្គបណ្តុះបណ្តាលព្រមទាំងស្រង់ទិន្នន័យដែលត្រូវធ្វើការបណ្តុះបណ្តាលនាពេលខាងមុខ ។

## ៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុប ចំនួន ៤ ៧៣១ ៨៣១ ៧៣៥ រៀល (បួនប៊ីលានប្រាំពីររយសាមសិបមួយលានប្រាំបីរយសាមសិបមួយពាន់ប្រាំពីររយសាមសិបប្រាំរៀល) ស្មើនឹង ១ ២០២ ១៨៣,៨៩ ដុល្លារអាមេរិក (មួយលានពីរយពីរពាន់មួយរយប៉ែតសិបបីដុល្លារនិងប៉ែតសិបប្រាំបួនសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុប

ចំនួន ៤ ៥៦២ នាក់នៅភូមិគោលដៅចំនួន ១៩៥ ភូមិ ៧១ ឃុំ ៣២ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥

- ចុះធ្វើអធិការកិច្ចលើគម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ
- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការរៀបចំគម្រោងសម្រាប់ស្នើសុំជំនួយហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលចិន ក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង ឆ្នាំ ២០១៩
- បានធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក្រ ស្ថិតនៅដៃសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦ នាក់ ស្រី ៦៤ នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើសិប្បកម្មផលិតសាប៊ូលាងចាន ចំនួន ០៦ វគ្គ នៅខេត្តកំពង់ធំ និងខេត្តត្បូងឃ្មុំ មានសិក្ខាកាមចូលរួមសរុបចំនួន ៦០ នាក់
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីគំនិតផ្តួចផ្តើម និងការគ្រប់គ្រងអាជីវកម្មខ្នាតតូច នៅខេត្តប៉ៃលិន មានសិក្ខាកាមចូលរួមសរុប ៣០ នាក់ ។

## ៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យឡើងវិញលើការងារកំណត់អត្តសញ្ញាណសហគមន៍ជនជាតិភាគតិចជង ចំនួន ០៥ សហគមន៍ នៅតំបន់អារ៉ែង ខេត្តកោះកុង ដែលមានភាពយឺតយ៉ាវនៅថ្នាក់ក្រោមជាតិ
- បានចូលរួមកិច្ចប្រជុំ ស្តីពីការបង្កើតក្រុមការងារដឹកនាំ និងអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិភាគតិច ជាមួយអង្គការដៃគូ (CIPO, CIYA)
- បានចូលរួម វាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយ ចំនួន ០៣ សហគមន៍ នៅឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ
- បានចូលរួមធ្វើបទបង្ហាញអំពីគោលនយោបាយអភិវឌ្ឍន៍ជនជាតិដើមភាគតិច សារាចរណ៍ណែនាំ ស្តីពីស្វ័យអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច និងដំណើរការរៀបចំបទបញ្ជាផ្ទៃក្នុងនៃការប្រើប្រាស់ និងគ្រប់គ្រងដីសហគមន៍ជនជាតិដើមភាគតិច ដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍ នៅសាលាស្រុករវៀង ខេត្តព្រះវិហារ
- ចូលរួមកិច្ចប្រជុំពិភាក្សាការងារជនជាតិដើមភាគតិច ជាមួយអង្គការដៃគូ អំពីគម្រោង និងទិសដៅបន្ត
- ទំនាក់ទំនងជាមួយអង្គការដៃគូ និងក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំធ្វើផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចតាមបណ្តាខេត្តទាំង ១៥ ។

## ៨. ការងារយេនឌ័រ

- បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី លក្ខន្តិកៈរបស់បណ្តាញសហគ្រិនស្ត្រីកម្ពុជា

- បានរៀបចំសិក្ខាសាលាស្តីពីការ ផ្សព្វផ្សាយទស្សនៈយេនឌ័រ អនុសញ្ញាស៊ីដ (CEDAW) និងអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងខេត្តកំពត
- បានចូលក្រាបថ្វាយបង្គំគាល់ព្រះករុណាជាអង្គម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងឱកាសអបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ ២០១៩
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីយេនឌ័រ និងកាបន្សាំនឹងការបម្រែបម្រួលអាកាសធាតុ
- រៀបចំកម្មវិធីអបអរសាទរខួបលើកទី ១០៨ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ ២០១៩ លើប្រធានបទ "លើកកម្ពស់សមភាពយេនឌ័រ និងការគាំពារសង្គម ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស" នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពី កិច្ចប្រតិបត្តិការ ផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្ត្រីក្រីក្រដែលរងគ្រោះដោយអំពើហិង្សា និងការអប់រំច្បាប់
- រៀបចំសិក្ខាសាលាស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចក្លាហានផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅតាមសហគមន៍ នៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ។

៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- បានរៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- បានចូលរួមសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងផែនការថវិកា ឆ្នាំ២០១៩ របស់ គ.ជ.អ.ប ក្រោមអធិបតីភាព សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ប្រជុំត្រួតពិនិត្យ និងស្តាប់របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៨ របស់ គ.ជ.អ.ប លើកកម្មវិធីអនាម័យលើស្រុកទាំង១៥
- ប្រជុំក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីពិភាក្សាលើមុខងារចំនួន ០៣ ដែលត្រូវផ្ទេរជូនទៅថ្នាក់ក្រោមជាតិ ដែលរួមមាន មុខងារថែទាំជួសជុលសំណង់ទឹកស្អាតជនបទ មុខងារផ្តល់សេវាអនាម័យរួមមានការសាងសង់បង្គន់អនាម័យសាធារណៈ និងមុខងារថែទាំផ្លូវ
- ប្រធានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការក្រសួងអភិវឌ្ឍន៍ជនបទ បានដឹកនាំមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់ក្រសួង ចូលរួមកិច្ចប្រជុំដើម្បីកំណត់មុខងារជាក់លាក់សម្រាប់ផ្ទេរឲ្យទៅរដ្ឋបាលក្រុង ស្រុក នៅលេខាធិការដ្ឋាន គ.ជ.អ.ប។

## IV. **ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ**

១. គម្រោងកែលម្អផ្លូវជនបទ ដំណាក់ ២



ស

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ គិតត្រឹមដំណាច់ត្រីមាសទី ១ នេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៤១,៣៦%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៤៨,៣៧%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៤១,២៣%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ៣៧,៨៨%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ២៣,៨១%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១២៥,៥០គ.ម សម្រេចបាន ៨៣,៩២%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ៨៦,៨១%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ៨២,០៤%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ១០០% ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហានទី ៦**

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទជំហានទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ ។ អង្គភាពគ្រប់គ្រងគម្រោងបានចល័តគ្រឿងចក្រដើម្បីដំណើរការសាងសង់ផ្លូវ ។

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ឆ្នាំ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទប្រវែងប្រមាណ ៦៨៧គីឡូម៉ែត្រ ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងខេត្តឧត្តរមានជ័យ ។ គម្រោងបាន និងកំពុងអនុវត្តចំនួន ១៦០ គម្រោង ប្រវែង ១៦២ ៤០៦ ម៉ែត្រ។



ក៖

៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២

- បានសាងសង់បង្គន់តាមខ្នងផ្ទះ ចំនួន ២៦ បង្គន់ នៅខេត្តតាកែវ
- បានចុះស្រង់ឈ្មោះគ្រួសារដែលទទួលបានបង្គន់គម្រោង ABC និងគ្រួសារដែលទទួលបានកំបោរ នៅឃុំគោកដូង ស្រុកសូទ្រនិគមន៍ ឃុំចាន់សរ ស្រុកអង្គរជុំ ខេត្តសៀមរាប
- សាងសង់អណ្តូងស្នប់ ចំនួន ០៥ នៅខេត្តពោធិ៍សាត់
- សាងសង់ថ្នាលហាលលាមកមានជំបូលថ្លាបេញ (Model3) នៅស្រុកសង្កែ ខេត្តបាត់ដំបង និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ សម្រេចបាន ៩៥%
- សាងសង់ថ្នាលហាលលាមកមានភ្ជាប់ឡជីវឧស្ម័ន (Model1) នៅសង្កាត់ចំការសំរោង ក្រុងបាត់ដំបង សម្រេចបាន ៧៥%
- ជួសជុលស្រះសហគមន៍ ចំនួន ០១ កន្លែង នៅខេត្តពោធិ៍សាត់
- បណ្តុះបណ្តាលអំពីអនាម័យតាមសាលារៀន (School WASH) និងការជួសជុល ថែទាំអណ្តូង (O & M) តាមភូមិនីមួយៗ ឃុំសែនសុខ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។

៥. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋ ប្រជាមានិតចិន

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទជំហាន ១ ក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន ដោយផ្តោតលើសកម្មភាពធំៗចំនួនពីរ គឺ ការផ្គត់ផ្គង់ទឹកជនបទដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ០៦ គឺ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ កណ្តាល ត្បូងឃ្មុំ និងខេត្តស្វាយរៀង និងការកែលម្អផ្លូវជនបទ ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ០៤ គឺ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ និងខេត្តកំពង់ចាម ។ គិតត្រឹមត្រីមាសទី ១ នេះ គម្រោងសម្រេចបាន៖

- បាន និងកំពុងសាងសង់ផ្លូវចំនួន ០៧ ខ្សែ ប្រវែង ៣៥,៥ គ.ម ក្នុងខេត្តគោលដៅទាំង ០៤ សម្រេច ១០០ %
- បានសាងសង់ស្ពានបេតុង ចំនួន ០១ ប្រវែង ១២៥ ម៉ែត្រ នៅខេត្តកំពង់ស្ពឺ សម្រេច ១០០%។

៦. លទ្ធផលសម្រេចបានពីកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល

ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ មានអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥២ កំពុងសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ។ គិតត្រឹមចុងខែមីនានេះ ក្រសួងបានទទួលរបាយការណ៍តែ ១៣ អង្គការប៉ុណ្ណោះដែលបានផ្ញើមកក្រសួងអភិវឌ្ឍន៍ជនបទ ។ លទ្ធផលដែលអង្គការសម្រេចបានក្នុងវិស័យអភិវឌ្ឍន៍ជនបទចម្បងៗរួមមាន ៖

- សាងសង់ផ្លូវបាន ២ ខ្សែ ស្ពានចំនួន ២ កន្លែង ស្រះទឹកចំនួន ២
- សាងសង់អណ្តូងស្នប់បាន ៦៩ អណ្តូង
- សាងសង់បង្គន់អនាម័យបានចំនួន ២៤៩៤ បង្គន់
- សាងសង់កន្លែងលាងសម្អាតដៃតាមសាលាបានចំនួន ៤៤កន្លែង
- សាងសង់ផ្ទះជូនប្រជាជនចំនួន ៣៣ ខ្នង
- សាងសង់ឡដុតសម្រាមចំនួន ២១ ឡ
- សាងសង់ធុងទឹកចម្រោះបាន ៣៥៣ ធុង អាងត្រងទឹកភ្លៀងចំនួន ៦ អាង



ជ

- ចែកម៉ាស៊ីនបូមទឹកចំនួន ៩ គ្រឿង
- បង្កើតផ្សារចល័តជនបទបានចំនួន ១២ កន្លែង
- បើកវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋាន ៣៨៧ វគ្គ
- បើកវគ្គបណ្តុះបណ្តាលជំនាញអភិវឌ្ឍន៍សហគមន៍ចម្រុះបានចំនួន ៧៤ វគ្គ

## V. សេចក្តីសន្និដ្ឋាន

ការដោះស្រាយបញ្ហាទឹកស្អាត និងទឹកប្រើប្រាស់នៅតាមសហគមន៍ជនបទ កំពុងត្រូវបានក្រសួងយកចិត្តទុកដាក់ជាអាទិភាពជាងគេក្នុងត្រីមាសទី១នេះ ។ មន្ត្រីជំនាញទទួលបន្ទុកទឹកស្អាត និងអនាម័យជនបទបានបន្តចុះតាមដានពិនិត្យកន្លែងដែលខ្វះប្រភពទឹក ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋឲ្យអស់លទ្ធភាព ដូចជាស្តារស្រះទឹក អណ្តូងទឹក បូមទឹក ចែកទឹកជូនប្រជាពលរដ្ឋដោះស្រាយបានទាន់ពេលវេលា ។ ការអនុវត្តផែនការថវិកាឆ្នាំ២០១៩ ទើបចាប់ដំណើរការបានខ្លះៗនៅឡើយនៅថ្នាក់កណ្តាល និងមន្ទីរមួយចំនួន កំពុងចាប់ផ្តើមសកម្មភាពរបស់ខ្លួនតាមផែនការដែលបានគ្រោងទុក ។ ក្នុងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈក្រសួងបានរៀបចំផែនការយុទ្ធសាស្រ្តថវិកា ២០២០-២០២២ ផែនការវិនិយោគសាធារណៈឆ្នាំ២០២០-២០២២ ពិសេសបានវិភាជន៍ថវិកាដល់ថ្នាក់ក្រោមជាតិ(ថ្នាក់ស្រុក)តាមកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ លើការងារជួសជុលផ្លូវជាលក្ខណៈប្រចាំ ការជួសជុលអណ្តូងទឹក ការបំផុសអនាម័យជនបទ និងសាងសង់បង្គន់អនាម័យសាធារណៈស្របតាមកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

ក្រសួងនៅតែបន្តផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋលើការងារស្ថាបនា ជួសជុលលើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គមនាគមន៍ជនបទក្នុងនោះមាន ការសាងសង់ ជួសជុល ថែទាំផ្លូវ ស្ពាន ប្រឡាយទឹក អណ្តូងទឹក ស្រះទឹក បង្គន់អនាម័យ និងបន្តអប់រំ ផ្សព្វផ្សាយសេវាទឹកស្អាត អនាម័យ ការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (ODF) រៀបចំទិវាលាងសម្អាតដៃ ការងារបរិស្ថានតាមភូមិ ដើម្បីជានាលើកកម្ពស់លក្ខខណ្ឌរស់នៅឲ្យបានល្អប្រសើរ ។ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋាន បង្កើតការងារ មុខរបរសម្រាប់អាជីវកម្មខ្នាតតូច តាមសហគមន៍ជនបទព្រមទាំងផ្តល់ឥណទានខ្នាតតូចដើម្បីបង្កើតមុខរបរសមស្របក្នុងសហគមន៍មូលដ្ឋានដូចមានចែងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជនបទឆ្នាំ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីលើកកម្ពស់គុណភាពនិងគុណតម្លៃជីវិតរបស់ប្រជាពលរដ្ឋឲ្យបានប្រសើរឡើង៕

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**